ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីភ្នាក់ងារជំនួយជាតិប្រយុទ្ធនឹងជំងឺអេដស៍
ក្រោមអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
លេខ :៣៤៣..អ.ជ.ប.ជ.អ.

ភ្នំពេញ, ថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ២០១៥

សេចក្តីសម្រេចចិត្ត
នៃកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី២ឆ្នាំ២០១៥

កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី២ឆ្នាំ២០១៥ បានដំណើរការរយៈពេលមួយព្រឹកពេញនា ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៥ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **អៀង ឃុលី** ទេសរដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដោយមានការចូលរួមពីសំណាក់ថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ប្រធានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍គ្រប់ក្រសួង ស្ថាប័ន រាជធានី ខេត្ត ប្រធានលេខាធិការដ្ឋានប្រយុទ្ធនឹងជំងឺអេដស៍រាជធានី ខេត្តទាំង២៥ និងដៃគូអភិវឌ្ឍន៍ រួមទាំងសង្គមស៊ីវិល សរុបចំនួន១២០រូប។

កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី២ បានដំណើរការស្របតាមអនុក្រឹត្យលេខ១០៩អនក្រ.បក ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ និងប្រកបដោយការចូលរួមពិភាក្សាផ្លាស់ប្តូរយោបល់ដ៏ទូលំទូលាយ ហើយបានសម្រេចចិត្តដូចតទៅ៖

១. ផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និង ពហុវិស័យឆ្លើយតបទៅនឹងមេរោគអេដស៍/ជំងឺអេដស៍លើកទី៤ឆ្នាំ២០១៥-២០២០ គឺជាយុទ្ធស្ត្រជាតិតែមួយគត់ត្រូវបានប្រើប្រាស់សម្រាប់ការងារប្រយុទ្ធនឹងជំងឺអេដស៍ក្នុងព្រះរាជាណាចក្រកម្ពុជា។

២. កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី២ បានសម្រេចនូវដំហានដែលត្រូវអនុវត្តដូចខាងក្រោម៖

ក. អ.ជ.ប.ជ.អ នឹងរៀបចំផែនការ៣ឆ្នាំរំកិលជាមួយតម្រូវការថវិកាចំណាយនិងពិនិត្យកេលទ្ធភាពធ្វើការសិក្សាអំពីសេណារីយោនិយោគក្នុងការងារអេដស៍ ឆ្ពោះទៅកាន់ការបិទបញ្ចប់ការរីករាលដាលមេរោគអេដស៍ឲ្យបានមុនឆ្នាំ២០៣០។

ខ. អ.ជ.ប.ជ.អ ក្រសួងផែនការ ក្រសួងមហាផ្ទៃ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទានឹងរៀបចំការកែសម្រួលនីតិវិធីផ្តល់បណ្ណក្រីក្រដោយគិតគូរពីបញ្ហាអេដស៍។

គ. អ.ជ.ប.ជ.អក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងផែនការ ក្រសួងមហាផ្ទៃ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នឹងរៀបចំបង្កើតកូដថវិកាការងារអេដស៍នៅថ្នាក់ឃុំសង្កាត់។

អាសយដ្ឋាន: អគារលេខ១៦ ផ្លូវលេខ ២៧១ ភែក ១៥០ សង្កាត់បឹងកេងកង៣ ខណ្ឌចំការមន រាជធានីភ្នំពេញ ទូរស័ព្ទ / ទូរសារ (៨៥៥-២៣) ៨៨៤ ១២៩

ឃ. អ.ជ.ប.ជ.អ ក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ និង ក្រសួងសុខាភិបាល ពិនិត្យលទ្ធភាពក្នុងការបង្កើនការវិនិយោគថវិកាជាតិក្នុងការឆ្លើយតបមេរោគអេដស៍/ជំងឺអេដស៍។

ង. ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបន្តដំព្រុងការអនុវត្តប្រកាសលេខ០៨៦ ក.ក.ប.វ/ប្រ.ក ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០០៦ ស្តីពីការបង្កើតគណៈកម្មការអេដស៍នៅតាមសហគ្រាសគ្រឹះស្ថាន និងការបង្ការទប់ស្កាត់មេរោគអេដស៍/ជំងឺអេដស៍នៅកន្លែងធ្វើការ និង ប្រកាសលេខ១៩៤ក.ប/ប្រ.ក ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៤ស្តីពីលក្ខខណ្ឌការងារ វិធានអនាម័យ និងសន្តិសុខការងារនៃសហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុនផ្នែកសេវាកម្មាន្ត។

ច. អ.ជ.ប.ជ.អ ក្រសួងសុខាភិបាល អាជ្ញាធរខេត្តជាប់ព្រំដែនកម្ពុជា–ថៃ (ខេត្តបន្ទាយមានជ័យ ខេត្តឧត្តរមានជ័យ ខេត្តប៉ៃលិន ខេត្តកោះកុង និងខេត្តដ៏ទៃផ្សេងទៀត) ពិនិត្យលទ្ធភាពធ្វើកិច្ចសហប្រតិបត្តការឆ្លើយតបមេរោគអេដស៍ ក្នុងចំណោមប្រជាជនចំណាកស្រុក។

ឆ. មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើរស្បែក និង កាមរោគ នឹងអនុវត្តវិធីសាស្ត្រប្រើប្រាស់ធនធានដើម្បីលទ្ធផលក្នុងការសម្រេចគោលដៅ៩០–៩០–៩០។

ជ. គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ខេត្តសៀមរាប និងខេត្តបាត់ដំបង នឹងអនុវត្តគម្រោងសាកល្បងដើម្បីសម្រេចគោលដៅ៩០-៩០-៩០។

ឈ. អ.ជ.ប.ជ.អ ក្រសួងមហាផ្ទៃ ក្រសួងអប់រំ យុវជន និង កីឡា ក្រសួងព័ត៌មាន និង ក្រសួងស្ថាប័នពាក់ព័ន្ធ ផ្តោតការជំរុញឲ្យបានខ្លាំងក្លានូវការអនុវត្តកម្មវិធីបង្ការការប្រើប្រាស់គ្រឿងញៀន និង ការចម្លងមេរោគអេដស៍ក្នុងចំណោមក្រុមយុវជន។

ញ. បន្តអនុវត្តគោលនយោបាយប្រាំពីរចំណុច តាមសារាចរលេខ២០៤៨សជណ ចុះថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ២០១៣ របស់រាជរដ្ឋាភិបាលកម្ពុជា។

កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី២ ឆ្នាំ២០១៥បានសម្រេចប្រគល់ភារកិច្ចជូនអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ដើម្បីដឹកនាំគ្រប់គ្រង សម្របសម្រួលអនុវត្តនូវការសម្រេចចិត្តនេះ ឲ្យមានប្រសិទ្ធភាពដើម្បីឆ្ពោះទៅសម្រេចបានជោគជ័យនូវ "គោលដៅ៩០-៩០-៩០៖ ១)៩០% នៃមនុស្សទាំងអស់ដែលមានផ្ទុកមេរោគអេដស៍បានដឹងពីស្ថានភាពផ្ទុកមេរោគអេដស៍របស់ពួកគេ ២)៩០%នៃអ្នកផ្ទុកមេរោគអេដស៍ទាំងអស់ដែលបានធ្វើរោគវិនិច្ឆ័យបានបន្តទទួលការព្យាបាលដោយឱសថប្រឆាំងនឹងមេរោគអេដស៍ជាប់ជាប្រចាំ៣) ៩០%នៃមនុស្សទាំងអស់ដែលទទួលព្យាបាលដោយឱសថប្រឆាំងនឹងមេរោគអេដស៍នឹងត្រូវរកឃើញថាបានកម្ចាត់មេរោគអេដស៍ពីក្នុងឈាមរបស់ខ្លួន"។

រាជធានីភ្នំពេញ ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៥

អៀង ម៉ូលី